# រដ្ឋលេខាធិការដ្ឋាន គ្រប់គ្រងបរិស្ថាន

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ១៩៩៤

## ប្រកាសលេខ ១០៣៣ បដ្ឋ
## រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញសេចក្តីសំរេចអនុម័តទុកចិត្តរបស់រដ្ឋសភា ស្តីពីសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៣
- បានឃើញភាពអាណាធិបតេយ្យក្នុងតំបន់ការពារធម្មជាតិ

**ប្រការ ១** : ហាមដាច់ខាតការកាត់តែងព្រៃគុប ការសាងសង់រោងចក្រអារឈើ ឡធ្យូង ឡអិដ្ឋ -ក្បឿង ឡកំបោរ ឡចំហុយថ្នាំជក់ នៅតំបន់ការពារធម្មជាតិ ។

**ប្រការ ២** : ហាមដាច់ខាតការបរបាញ់ ដាក់អន្ទាក់ អង្គប់ ចាប់សត្វព្រៃគ្រប់ប្រភេទ និងការនេសាទ មានជាអាទិ៍ ពពួកសត្វថនិកសត្វ ឧរង្គសត្វ ថលជលិកសត្វ និងវារីសត្វ ដើម្បីយកសាច់ ភ្លុក ឆ្អឹង ស្បែក ស្នែង ស្បែក រោម និងឈាម និងការបរបាញ់ជាលក្ខណៈកីឡា ។

**ប្រការ ៣** : ហាមដាច់ខាតការកាប់គាស់រុករាន ឆ្ការព្រៃ ដុតព្រៃ ដើម្បីយកដីសាងសង់លំនៅដ្ឋាន ធ្វើស្រែ ចំការ ពង្រីកដីកម្មសិទ្ធឯកជន រឺ អង្គភាព នៅក្នុងតំបន់ការពារធម្មជាតិ ។

**ប្រការ ៤** : ហាមដាច់ខាតការរុករក និងធ្វើអាជីវកម្ម រ៉ែគ្រប់ប្រភេទ និងការប្រើប្រាស់ គ្រឿងផ្ទុះ នៅក្នុងតំបន់ការពារធម្មជាតិ ។

**ប្រការ ៥** : ហាមដាច់ខាតការនាំសត្វពាហនៈ មានសត្វឆ្កែជាដើមចូលទៅតំបន់ការពារធម្មជាតិ ។

**ប្រការ ៦** : ហាមដាច់ខាតការបំផ្លាញគុណភាពទឹក នៅក្នុងតំបន់ការពារធម្មជាតិ ដូចជាការប្រើប្រាស់គ្រឿងផ្ទុះ ការដាក់ថ្នាំបំពុល ការប្រើសារធាតុគីមី ការប្រើចរន្តអគ្គិសនី ការចោលកាកសំណល់រឹង និងរាវ ចូលក្នុងទឹក រឺ លើដី ។

**ប្រការ ៧** : ហាមដាច់ខាតការប្រើប្រាស់គ្រឿងចក្រ រថយន្តធុនធំ វិទ្យុ ឧបករណ៍សូរសព្ទ ដែលបញ្ចេញ ផ្សែង សំលេង និងបំពងសំលេង ធ្វើអោយប៉ះពាល់ និងបាត់បង់លក្ខណៈធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិ ។

**ប្រការ ៨** : ការស្រាវជ្រាវ ដកស្រង់ពិសោធន៍ដែលពាក់ព័ន្ធដល់តំបន់ការពារធម្មជាតិ ត្រូវមានការអនុញ្ញាតិពីរដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិដ្ឋាន ។

**ប្រការ ៩** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១០** : ជនណាដែលប្រព្រឹត្តល្មើសនឹងសេចក្តីប្រកាសខាងលើនេះត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ ១១** : នាយកដ្ឋានការពារអភិរក្សធម្មជាតិនៃរដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិដ្ឋាន គ្រប់ខេត្តក្រុង កងកំលាំងប្រដាប់អាវុធ ដែលប្រចាំការនៅតំបន់ការពារធម្មជាតិត្រូវអនុវត្តន៍សេចក្តីប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**បណ្ឌិត ម៉ុក ម៉ារ៉េត**

* * *